




# សាររអបអរសាទរ
# របស់ឯកឧត្តម Wang Wentian ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា

**ជនរួមជាតិ និងមិត្តភក្តិទាំងឡាយជាទីនឹករឭក**

ថ្ងៃនេះ ជាថ្ងៃរំឭកខួបអនុស្សាវរីយ៍នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន។ ក្នុងឱកាសដ៏សែនឱឡារិក និងឧត្តុង្គឧត្តមនេះ ខ្ញុំសូមតំណាងស្ថានទូតចិនប្រចាំកម្ពុជា សម្តែងគារវកិច្ចដោយស្មោះជូនចំពោះបុគ្គលិកនៃសហគ្រាសចិនក្នុងប្រទេសកម្ពុជា គ្រូបង្រៀនភាសាចិន និងអ្នកស្ម័គ្រចិត្តចិនក្នុងប្រទេសកម្ពុជា និស្សិតចិនក្នុងប្រទេសកម្ពុជា និងព្រមទាំងប្រជាជនចិននៅក្នុងប្រទេសកម្ពុជា និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះមិត្តភក្តិកម្ពុជាគ្រប់មជ្ឈដ្ឋានដែលតែងយកចិត្តទុកដាក់ និងគាំទ្រដល់ការអភិវឌ្ឍរបស់ប្រទេសចិន និងបានចូលរួមជាកម្លាំងជំរុញមិត្តភាពជាប្រពៃណីរវាងចិន និងកម្ពុជា!

កាលពី ៧១ ឆ្នាំមុន ស្ថិតក្រោមការដឹកនាំរបស់គណបក្សកុម្មុយនីស្តចិន ប្រជាជនចិនទូទាំងប្រទេសបានឆ្លងកាត់ និងពុះពាររាល់ឧបសគ្គដ៏កាចសាហាវ បានផ្តួលរំលំចក្រពត្តិនិយម សក្តិភូមិនិយម និងមូលធននិយម ការិយាធិបតេយ្យបានយ៉ាងជោគជ័យដែលប្រៀបដូចជាភ្នំដ៏ធ្ងន់ចំនួន៣ធំៗ និងសម្រេចបានបដិវត្តន៍ប្រជាធិបតេយ្យនិយមថ្មីផងដែរ។ ការបង្កើតសាធារណរដ្ឋប្រជាមានិតចិន បានបង្ហាញឱ្យឃើញពីការក្រោកឈរឡើងនៃប្រជាជនចិនចាប់តាំងពីពេលនោះមក ហើយប្រជាជនចិនបានដើរលើមាគ៌ាសម្រេចនូវភាពរុងរឿងដ៏អស្ចារ្យយ៉ាងធំទូលំទូលាយ។

រយៈពេល ៧១ឆ្នាំនេះ ក្រោមការដឹកនាំរបស់គណបក្សកុម្មុយនីស្តចិន ប្រជាជនចិនបានខិតខំប្រឹងប្រែងដោយផ្ទាល់ខ្លួន បានជម្នះរាល់ឧបសគ្គ និងរាល់ការលំបាក បានឆ្លងផុតរាល់រនាំង និងឧបសគ្គពីមួយទៅមួយ បានបង្កើតសមិទ្ធផលធំៗ និងល្បីៗជាច្រើនគួរឱ្យកត់សម្គាល់។ ប្រជាជនចិនសម្រេចបានសម្ទុះដ៏លឿនមហិមាបំផុតក្នុងការក្រោកឈរឡើងសម្បូរហូរហៀរឡើង និងដ៏ខ្លាំងក្លា។ នាឆ្នាំនេះ ប្រទេសចិននឹងកសាងសង្គមដែលប្រជាជនមានជីវភាពធូរធារបង្គួរគ្រប់ជ្រុងជ្រោយ សម្រេចបាននូវគោលដៅ១០០ឆ្នាំទី១។ ប្រទេសចិននាពេលបច្ចុប្បន្ននេះកាន់តែខិតជិតទៅរកការសម្រេចបាននូវគោលដៅនៃភាពរីកចម្រើនដ៏មហិមាជាងពេលណាៗទាំងអស់។


**ឯកឧត្តម** Wang Wentian **ឯកអគ្គរដ្ឋទូតចិនប្រចាំព្រះរាជាណាចក្រកម្ពុជា។**

មិត្តភក្តិទាំងអស់ជាទីរាប់អាន នាដើមឆ្នាំ២០២០ មានការផ្ទុះឡើងនូវជំងឺវីរុសកូវីដ១៩។ ការប្រឈមមុខជាមួយនឹងជំងឺវីរុសដ៏កាចសាហាវមួយនេះ ក្រោមការដឹកនាំដ៏រឹងមាំរបស់គណបក្សកុម្មុយនីស្តចិនដែលមានឯកឧត្តម Xi Jinping ជាស្នូលយើងតែងតែប្រកាន់ខ្ជាប់នូវគោលការណ៍យកប្រជាជនជាធំ បានចាប់ផ្តើមសង្គ្រាមប្រយុទ្ធប្រឆាំងជាមួយនឹងជំងឺវីរុសមួយនេះដែលបានចូលរួមដោយប្រជាជនចិន។ ប្រទេសចិនទទួលបានសមិទ្ធផលផ្លែផ្កាយុទ្ធសាស្ត្រសំខាន់ៗក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺវីរុសក្នុងរយៈពេលដ៏ខ្លី ហើយធានាបានអាយុជីវិត សុខភាព និងសុវត្ថិភាពប្រជាជនចិនយ៉ាងមានប្រសិទ្ធភាព និងជាគំរូដ៏ល្អសម្រាប់កិច្ចប្រយុទ្ធប្រឆាំងនឹងជំងឺវីរុសជាសកលមួយនេះ។

ប្រទេសចិននៅអំឡុងពេលបំពេញការងារទប់ស្កាត់នឹងជំងឺវីរុស បានផ្តួចផ្តើមយ៉ាងសកម្មក្នុងការកសាងសហគមន៍សុខាភិបាលសម្រាប់មនុស្សជាតិរួម បានគាំទ្រយ៉ាងពេញទំហឹងនិងចូលរួមក្នុងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងជំងឺវីរុសមួយនេះជាអន្តរជាតិ នេះបានបង្ហាញឱ្យឃើញពីការទទួលខុសត្រូវរបស់ចិនដែលជាប្រទេសមហាអំណាច។ ប្រទេសចិនបានផ្តល់ជំនួយជាង ២ ពាន់លានដុល្លារអាមេរិកដល់សហគមន៍អន្តរជាតិ។ រដ្ឋាភិបាលចិននឹងអនុវត្តការប្តេជ្ញាចិត្តដ៏អស្ចារ្យរបស់ឯកឧត្តម ប្រធានាធិបតីចិន Xi Jinping ក្នុងកិច្ចចាត់ទុកវ៉ាក់សាំងចិន ជាផលិតផលសាធារណៈអន្តរជាតិ និងការរួមចំណែករបស់ចិន ដើម្បីសម្រេចបាននូវលទ្ធភាពទទួលយកបាន និងការទទួលខុសត្រូវលើវ៉ាក់សាំងកូវីដ១៩សម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍន៍។

ប្រឈមមុខនឹងការតេស្តសាកល្បងនៃជំងឺវីរុសមួយនេះ និងបរិយាកាសអន្តរជាតិដ៏ស្មុគស្មាញនិងផ្លាស់ប្តូរឥតឈប់ឈរ ប្រទេសចិនបានរៀបចំគម្រោងជំរុញកិច្ចទប់ស្កាត់នឹងជំងឺវីរុស និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម បានជំរុញយ៉ាងខ្លាំងនូវគំរូថ្មីដែលផ្តោតសំខាន់លើវដ្តក្នុងប្រទេសជាតិជាគោល និងការជំរុញគ្នាទៅវិញទៅមកវដ្តទ្វេដងក្នុងប្រទេស និងអន្តរជាតិ និងបានជំរុញកិច្ចស្តារអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និងទទួលបានសមិទ្ធផលជាក់ស្តែងជាច្រើនគួរឱ្យកត់សម្គាល់។ យោងតាមតួលេខបង្ហាញឱ្យឃើញថា ក្នុងត្រីមាសទី២ នាឆ្នាំនេះ GDP របស់ប្រទេសចិនបានកើនឡើង ៣,២ % បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានព្យាករថា ប្រទេសចិននឹងក្លាយជាតួសេដ្ឋកិច្ចសំខាន់តែ១គត់ដែលអាចរក្សាបាននូវកំណើនសេដ្ឋកិច្ចវិជ្ជមានពេញ១ឆ្នាំ២០២០ ហើយយើងពិតជាមានមោទនភាពយ៉ាងខ្លាំង។

មិត្តភក្តិទាំងឡាយជាទីរាប់អាន ឆ្នាំនេះគឺជាខួបអនុស្សាវរីយ៍លើកទី ១០ នៃការបង្កើតកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរវាងចិននិងកម្ពុជា ហើយក៏ជាខួបអនុស្សាវរីយ៍លើកទី១ នៃការចុះហត្ថលេខាអនុវត្តផែនការសកម្មភាពកសាងសហគមន៍ជោគវាសនារួមរវាងប្រទេសទាំង២ផងដែរ។ ប្រឈមមុខជាមួយនឹងជំងឺវីរុស ប្រទេសចិននិងកម្ពុជា រដ្ឋាភិបាលនិងប្រជាជនទាំង២ប្រទេស តែងពួតដៃគ្នា ពុះពាររាល់ការលំបាក បង្កើតបានជាគំរូដ៏ប្រពៃសម្រាប់កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងជំងឺវីរុសលើឆាកអន្តរជាតិ។ ក្នុងអំឡុងពេលនៃការផ្ទុះឡើងនូវជំងឺវីរុសកូវីដ១៩ មួយនេះ ភាគីទាំង២បានបង្កើតរួមគ្នានូវកិច្ចការទី១ជាច្រើន។

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺជាប្រមុខរដ្ឋាភិបាលបរទេសទី១ ដែលបានបំពេញទស្សនកិច្ចក្នុងប្រទេសចិន។ ជំនួយសម្ភារទប់ស្កាត់នឹងជំងឺវីរុសលើកដំបូងដែលទីក្រុង Wuhan ខេត្ត Hubei ប្រទេសចិន ទទួលបានគឺមកពីប្រទេសកម្ពុជា។ រដ្ឋាភិបាលចិន និងកងទ័ពចិនបានបញ្ជូនក្រុមអ្នកជំនាញវេជ្ជសាស្ត្រទប់ស្កាត់នឹងជំងឺវីរុសលើកដំបូងគេក្នុងតំបន់ឬសកលលោក គឺមកកាន់ប្រទេសកម្ពុជា។ កិច្ចចរចាពាណិជ្ជកម្មសេរីរវាងចិននិងកម្ពុជា ជាកិច្ចចរចាពាណិជ្ជកម្មសេរីទី១ត្រូវបានបញ្ចប់ដោយតាមរយៈ Video Conference។ សមយុទ្ធ"នាគមាស-២០២០" គឺជាលំហាត់រួមគ្នាតែ១គត់ដែលធ្វើឡើងដោយភាគីចិនជាមួយនឹងកងទ័ពភាគីកម្ពុជា។ កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលរវាងចិននិងកម្ពុជាលើកទី៥ ជាកិច្ចប្រជុំកិច្ចសហប្រតិបត្តិការយន្តការទ្វេភាគីកម្រិតកំពូលទី១ដែលរៀបចំរវាងចិននិងប្រទេសជិតខាង។ ភាពជាក់ស្តែងជាច្រើនរាប់មិនអស់ត្រូវបានបង្ហាញឱ្យឃើញពីមិត្តភាពជាប្រពៃណីរវាងចិននិងកម្ពុជាត្រូវបានកែលម្អថែមមួយកម្រិតទៀត បន្ទាប់ពីឆ្លងកាត់ការដុសខាត់នៃជំងឺវីរុសមួយនេះ។

មិត្តភក្តិទាំងអស់ជាទីរាប់អាន ពិភពលោកនាពេលបច្ចុប្បន្ននេះកំពុងឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងខ្លាំងដែលមិនធ្លាប់មានក្នុង១សតវត្សរ៍នេះ។ ពិភពលោកកំពុងឈរនៅចំណុចចាប់ផ្តើមប្រវត្តិសាស្ត្រថ្មីមួយ។ ជោគវាសនារបស់មនុស្សជាតិមានទំនាក់ទំនងស្អិតល្មួតដែលពុំធ្លាប់មានដូចសព្វថ្ងៃនេះទេ។ ប្រទេសចិននឹងបន្តពង្រីកការបើកចំហទៅកាន់ពិភពលោកខាងក្រៅ រួបរួមសាមគ្គីគ្នាជាមួយបណ្តាប្រទេសក៏ដូចជាប្រទេសកម្ពុជាផងដែរ ពង្រីកសមិទ្ធផលកិច្ចសហប្រតិបត្តិការជោគជ័យរួមគ្នាកាន់តែធំ។ ប្រទេសចិននឹងដើរតួជាអ្នកអនុវត្តពហុភាគីនិយម បន្តជំរុញការកសាងសហគមន៍ជោគវាសនារួមសម្រាប់មនុស្សជាតិគ្រប់រូប សម្រេចបានការសាមគ្គីគ្នា និងភាពរីកចម្រើនកាន់តែធំសម្រាប់សង្គមមនុស្សជាតិ!

**សូមជូនពរប្រទេសចិន និងកម្ពុជារីកចម្រើនថ្កុំថ្កើន និងអភិវឌ្ឍ ប្រជាជនរស់នៅដោយសុខក្សេមក្សាន្ត!**

**សូមជូនពរមិត្តភាពចិននិងកម្ពុជាដែលប្រៀបដូចបងប្អូន យូរអង្វែងជាអមតៈ!**

# អបអរសាទរខួបនៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិនលើកទី៧១



លោក Yum Sui Sang ប្រធានសមាគម CHKMEBA។




សមាគម CHKMEBA ផ្តល់ជំនួយវេជ្ជសាស្ត្រដល់កម្ពុជា។

ក្នុងឱកាសពិធីបុណ្យសែនព្រះខែ (Mid-Autumn Festival) យើងប្រារព្ធខួបនៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិនលើកទី៧១។

នៅថ្ងៃដ៏ពិសេសនិងស្រស់បំព្រងសមាជិកទាំងអស់នៃសមាគមពាណិជ្ជកម្ម អាណិកជនចិនហុងកុង និងម៉ាការ នៅកម្ពុជានិងរូបខ្ញុំសូមជូនពរដោយស្មោះអស់ពីដួងចិត្តចំពោះប្រទេសរបស់យើងឱ្យកាន់តែរីកចម្រើនរុងរឿង និងសូមជូនពរប្រជាជនយើងឱ្យរស់នៅដោយក្តីសុខដុមរមនា! សូមជូនពរជនរួមជាតិហុងកុង ម៉ាការ និងប្រជាជនចិននៅក្នុងប្រទេសកម្ពុជា ឱ្យទទួលបាននូវក្តីសុខ និងសប្បាយរីករាយក្នុងឱកាសបុណ្យសែនព្រះខែ។

ចាប់តាំងពីការបង្កើតសាធារណរដ្ឋប្រជាមានិតចិនក្នុងឆ្នាំ១៩៤៩មកគឺមានការផ្លាស់ប្តូរដ៏អស្ចារ្យក្នុងរយៈពេល ៧១ ឆ្នាំមកនេះ ដែលបានអនុញ្ញាតឱ្យពិភពលោកមើលឃើញពីសម្ទុះនៃការរីកចម្រើនរបស់ប្រទេសចិន ចាប់តាំងពីការបិទ និងអន់ថយ រហូតដល់បើកចំហ និងរីកចម្រើនដ៏ខ្លាំងក្លាដែលមិនធ្លាប់មានពីមុន នៅលើឆាកអន្តរជាតិ។

ចាប់តាំងពីក្រីក្រ រហូតដល់ក្លាយជាប្រទេសមហាអំណាច មានសេដ្ឋកិច្ចធំបំផុតលំដាប់ទី២នៅលើពិភពលោក ប្រទេសចិនបានចំណាយពេលតែប៉ុន្មានទសវត្សរ៍ប៉ុណ្ណោះដើម្បីបញ្ចប់ដំណើរការឧស្សាហូបនីយកម្ម ដែលប្រទេសអភិវឌ្ឍន៍ជាច្រើនបានឆ្លងកាត់រាប់រយឆ្នាំ។

ដោយស្មារតីនិងឆន្ទៈដ៏មោះមុតប្រជាជនចិនបានកសាងប្រទេសចិនឱ្យក្លាយទៅជាប្រទេសមហាអំណាចដ៏អស្ចារ្យ និងទំនើបមួយ ហើយប្រជាជាតិចិនកំពុងឈរនៅលំដាប់ខ្ពស់ក្នុងចំណោមប្រជាជាតិនានាលើពិភពលោក។ ឆ្នាំ២០២០គឺជាឆ្នាំដ៏លំបាកមួយសម្រាប់ប្រទេសចិន និងពិភពលោក។

ការផ្ទុះឡើងភ្លាមៗនៃជំងឺកូវីដ១៩ បណ្តាលឱ្យប៉ះពាល់យ៉ាងខ្លាំងដល់មនុស្សជាតិទាំងអស់។

បន្ទាប់ពីការតស៊ូដ៏លំបាកនិងការលះបង់ដ៏ធំធេងអស់រយៈពេលជាង២ ខែ នៅទីបំផុតប្រទេសចិនបានទទួលជោគជ័យយ៉ាងខ្លាំង នៅក្នុងការគ្រប់គ្រងជំងឺរាតត្បាតមួយនេះនិងបានផ្តល់នូវជំនួយដ៏មានតម្លៃសម្រាប់ការការពារ និងទប់ស្កាត់ជំងឺរាតត្បាតមួយនេះ សម្រាប់ប្រទេសជាច្រើននៅជុំវិញពិភពលោក។

ក្រឡេកមើលអតីតកាលវិញ, យើងបានដើរជាមួយសម្ទុះដ៏ខ្លាំងក្លាហើយគ្រប់ជំហាននីមួយៗ គឺពោរពេញទៅដោយទុក្ខលំបាក។

ចំពោះថ្ងៃអនាគត យើងនៅតែអាចប្រឈមនឹងហានិភ័យនិងបញ្ហាប្រឈមមួយចំនួន ប៉ុន្តែយើងតែងតែជឿជាក់ថា មិនថាមានភ្លៀងខ្យល់ ឬឧបសគ្គបែបណានោះទេ គឺមិនអាចបញ្ឈប់ប្រជាជនចិនពីការធ្វើដំណើរឆ្ពោះទៅមុខដើម្បីស្វែងរកជីវិតដ៏ប្រសើរនិងសម្រេចក្តីសុបិននៃការកសាងឡើងវិញដ៏អស្ចារ្យរបស់ប្រជាជាតិចិនបានទេ។

អបអរសាទរ ខួបនៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន!

សូមឱ្យចំណងមិត្តភាពរវាងប្រទេសចិននិងកម្ពុជាស្ថិតស្ថេរជានិរន្តរ៍ និងមិនប្រួលប្រែ។ ■

**លោក** Yum Sui Sang **ប្រធានសមាគមពាណិជ្ជកម្ម អាណិកជនចិនហុងកុង និងម៉ាកែវ នៅកម្ពុជា**

Yi Sang has been bringing the flavours of Guangdong province to the Kingdom of Cambodia since 2008; celebrating its 12th anniversary recently. Brainchild of Cambodian Master Chef, Luu Meng, Yi Sang restaurants are well known today amongst the locals and Chinese community as a restaurant to enjoy delectable Cantonese cuisine for lunch and dinner whilst as the preferred dim sum and noodle place for breakfast. It serves highest quality Cantonese dishes and adapting old cuisine customs to modern palates, with innovative food pairings.

Lunch and dinner menu highlights include its signature Crispy Roast Duck made with forest honey from Cambodia, organic Kulen black pig sourced from the sacred Kulen mountain and seasonal favourites like 'Bang Kang', Mekong River lobsters.

Thousands of years ago, Chinese has founded the healing power of healthy soup and used soup as medicine for centuries till today, this is why soups and broths hold a special place in both Chinese cuisine and traditional medicine. In today's fast pace world, including Cambodia, a young growing nation, where both parents are working, there is hardly time for family meals together let alone time to make slow-cook soup. This is where Yi Sang restaurants come in to fill the gap.

Yi Sang's unbeatable and popular 12-hour slow cooked soups with rare ingredients like lingzhi, cordyceps, special Chinese herbs are believed to detoxify, reduce blood pressure or nourish the organs. Drinking the right Chinese soup is also thought to restore the balance of yin and yang in the body.

Spread strategically across Phnom Penh, Yi Sang outlets are located at Sothearos Boulevard (flagship), Sisowath Quay and Toul Kork.



# សករាជថ្មី សម្រាប់ទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា-ចិន

ទំនាក់ទំនងសេដ្ឋកិច្ចរវាងកម្ពុជា-ចិនកំពុងឈានដល់គំរូថ្មីមួយទៀតជាមួយនឹងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី( FTA ) លើកដំបូងក្នុងឆ្នាំនេះជាមួយប្រទេសមហាអំណាចសេដ្ឋកិច្ចជិតខាង។

ភាពស្របគ្នាខាងសេដ្ឋកិច្ច ដែលមានភាពរួសរាយរាក់ទាក់និងឧត្តមគតិរួមបានរួមចំណែកដល់បរិយាកាសពាណិជ្ជកម្មកាន់តែដំណើរការល្អ ជាមួយនឹងការវិនិយោគធំៗរបស់ប្រទេសចិនដែលជំរុញដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាច្រើនទសវត្សរ៍មកនេះ។

ពាណិជ្ជកម្មទ្វេភាគីបានកើនឡើងដល់ ៩,៤៣ ពាន់លានដុល្លារកាលពីឆ្នាំមុន ធៀបទៅនឹងឆ្នាំ២០១៨ មានទំហំទឹកប្រាក់ ៧,៤ ពាន់លានដុល្លារ ដែលកើនឡើង ២៧,៧ ភាគរយ។

ឯកឧត្តម ងួន ម៉េងតិច អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជាបានឱ្យភ្នំពេញប៉ុស្ដិ៍ដឹងថា៖«កម្ពុជាគួរតែទាញយកអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសចិននៅក្នុងផ្នែកដែលអាចបំពេញបន្ថែមដល់ប្រទេសចិន។ នៅទីបំផុតផលិតផលកសិកម្មកម្ពុជាអាចត្រូវបាននាំចេញដោយផ្ទាល់ទៅកាន់ប្រទេសចិន ដោយមិនចាំបាច់ឆ្លងកាត់តាមរយៈប្រទេសទី៣ទៀតទេ»។

ក្រុមហ៊ុនចិនទាំងរដ្ឋ និងសហគ្រាសឯកជន បានចូលរួមចំណែកយ៉ាងច្រើនក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ថាមពល អចលនទ្រព្យ និងកសិកម្មរបស់ប្រទេសកម្ពុជា។

តាមរយៈ FTA នេះ វានឹងក្លាយជាការផ្លាស់ប្ដូរដ៏ធំមួយ ខណៈការយកពន្ធគយនឹងត្រូវបានកាត់បន្ថយ ដែលនឹងអនុញ្ញាតឱ្យក្រុមហ៊ុននាំចេញកម្ពុជាទទួលបានទីផ្សារកាន់តែច្រើនសម្រាប់ផលិតផលរបស់ខ្លួន ដែលវាមានសារៈសំខាន់ណាស់ក្នុងអំឡុងពេលមានបញ្ហា ជំងឺកូវីដ១៩ ដែលបានរាំងខ្ទប់ដល់លំហូរពាណិជ្ជកម្ម។

នៅពេលដែល FTA ចាប់ផ្ដើម ទំនិញកម្ពុជាប្រហែល ៣៤០ មុខពីកម្ពុជានឹងត្រូវបានរួចផុតពីការយកពន្ធដូចជាម្រេច ខ្ទឹមស ម្ទេសក្រៀម គ្រាប់ស្វាយចន្ទី ទឹកឃ្មុំនិងគ្រឿងសមុទ្រជាដើម។ តាមរយៈកិច្ចព្រមព្រៀងនេះនឹងជំរុញដល់កំណើនសេដ្ឋកិច្ចនៅជនបទ ដែលប្រជាជន៨០ភាគរយពឹងផ្អែកលើវិស័យកសិកម្ម។

កិច្ចព្រមព្រៀងនេះគ្របដណ្ដប់លើទំនិញនិងសេវាកម្ម កិច្ចសហប្រតិបត្តិការវិនិយោគ ពាណិជ្ជកម្មអេឡិចត្រូនិក កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសព្រមទាំងគំនិតផ្ដួចផ្ដើមផ្លូវមួយខ្សែក្រវាត់មួយផងដែរ។ ភាគីទាំង២បានបញ្ចប់ការចរចា FTA របស់ពួកគេនៅថ្ងៃទី២០ ខែកក្កដា។



**ឯកឧត្តម ងួន ម៉េងតិច អគ្គនាយកសភាពាណិជ្ជកម្មកម្ពុជា។**

ឯកឧត្តមបន្ថែមថា៖«ប្រទេសកម្ពុជានៅតែមានភាពទាក់ទាញដល់វិនិយោគិននិងសហគ្រិនចិន។ ទំនាក់ទំនងសេដ្ឋកិច្ចរវាងប្រទេសទាំង២កាន់តែមានភាពប្រសើរឡើងនិងត្រូវបានលើកកម្ពស់។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) នឹងទាក់ទាញសកម្មភាពអាជីវកម្មចិនកាន់តែច្រើន»។

ឯកឧត្តម ម៉េងតិច បានគូសបញ្ជាក់ថា៖«ពាណិជ្ជកម្មទ្វេភាគីបាននិងកំពុងដំណើរការទៅយ៉ាងរលូន ហើយនៅឆ្នាំនេះប្រទេសទាំង២បានចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលនឹងជួយជំរុញពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី។

ក្នុងឆ្នាំ២០១៩ ពាណិជ្ជកម្មទ្វេភាគីបានឈានដល់៩,៤ពាន់លានដុល្លារ។ ទាំងវិស័យឯកជន និងរដ្ឋបានចូលរួមចំណែកយ៉ាងច្រើនដល់សេដ្ឋកិច្ចក្នុងស្រុក ទាក់ទងនឹងការផ្ទេរបច្ចេកវិទ្យា ការលើកកម្ពស់ជំនាញរបស់កម្លាំងពលកម្មកម្ពុជា និងការបង្កើតការងារ»៕ ■

The Phnom Penh Post ភ្នំពេញ ប៉ុស្ដិ៍

យើងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកឧបត្ថម្ភទាំងអស់ដែលបាន
ជួយដល់ការបោះពុម្ពផ្សាយរបាយការណ៍ពិសេស
ខួបអនុស្សាវរីយ៍នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិនលើកទី៧១



HKBAC 柬埔寨香港商會 Hong Kong Business Association of Cambodia
Hong Kong Economic and Trade Office in Bangkok
The Government of the Hong Kong Special Administrative Region
YI SANG chinese restaurant
sevensea SEAFOOD RESTAURANT
WORLD DINING RESTAURANT
ALLNISON Auditing and Consulting Co.,Ltd
REANDA Reanda LLKG (Cambodia) Co., Ltd
MINGFAI
wmc
Tropicam
Tropicam
ONL
URBAN VILLAGE
dynamic

# ចិនផ្តល់ជំនួយដើម្បីចូលរួមអភិវឌ្ឍប្រទេសកម្ពុជា






## គម្រោងហេដ្ឋារចនសម្ព័ន្ធ

គម្រោងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតាមជនបទនៃប្រទេសកម្ពុជា ដំណាក់កាលទី២ សាងសង់ដោយក្រុមហ៊ុន Yunan Construction and Investment Holding Group Co., Ltd ( YCIH )។ គោលបំណងនៃគម្រោងដំណាក់កាលទី២ ដែលសាងសង់ដោយក្រុមហ៊ុន Yunan Construction and Investment Holding Group Co., Ltd ( YCIH ) គឺដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅតំបន់ជនបទនៃប្រទេសកម្ពុជា ដែលអាចជួយកាត់បន្ថយភាពក្រីក្រ ធ្វើឲ្យសេដ្ឋកិច្ចជនបទ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជននៅតំបន់ដាច់ស្រយាលកាន់តែប្រសើរឡើង។ ខេត្តមួយចំនួនដែលទទួលបានអត្ថប្រយោជន៍ពីគម្រោងនេះគឺខេត្តត្បូងឃ្មុំ ព្រៃវែង និងស្វាយរៀង។ ប្រទេសចិនគ្រោងនឹងផ្តល់ជំនួយហិរញ្ញវត្ថុដល់គម្រោងផ្លូវនៅតំបន់ជនបទនៃប្រទេសកម្ពុជា ដើម្បីជួសជុល និងធ្វើឱ្យប្រសើរឡើងនូវផ្លូវដែលមានស្រាប់៕






## ចិនផ្តល់ជំនួយសម្រាប់គម្រោងទឹកស្អាត នៅតំបន់ជនបទដំណាក់កាលទី២

ចិនផ្តល់ជំនួយដល់កម្ពុជា ក្នុងការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទក្នុងដំណាក់កាលទី២ ដែលមូលនិធិនេះជាជំនួយឥតសំណងរបស់រដ្ឋាភិបាលចិន បានចាប់ផ្តើមនៅខែវិច្ឆិកាឆ្នាំ២០១៩ ហើយគ្រោងនឹងបញ្ចប់ក្នុងរយៈពេល២ឆ្នាំ។ គម្រោងសរុបមានចំនួន ៩៦៤ អណ្តូង និងស្រះទឹកសហគមន៍ចំនួន ៥៤ ត្រូវបានសាងសង់ក្នុងខេត្តចំនួន១០។ ខេត្តទាំងនោះរួមមាន ព្រៃវែង ស្វាយរៀង កំពង់ចាម កំពង់ស្ពឺ បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពត។ ហេដ្ឋារចនាសម្ព័ន្ធទាំងនេះនឹងផ្តល់ទឹកស្អាត មានអនាម័យសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ ប្រព័ន្ធធារាសាស្ត្រសម្រាប់កសិកម្ម និងសម្រាប់ការចិញ្ចឹមសត្វសម្រាប់ប្រជាជននៅតាមជនបទរាប់ពាន់នាក់៕

# ចិនសាងសង់មន្ទីរពេទ្យលើផ្ទៃដី ៧,៦ ហិកតា នៅខេត្តត្បូងឃ្មុំ

ហេដ្ឋារចនាសម្ព័ន្ធជំនួយវេជ្ជសាស្ត្រធំបំផុតទី២របស់ចិន ដែលមានទំហំ ២៤ ៣០០ ម៉ែត្រការ៉េសាងសង់នៅលើផ្ទៃដី ៧,៦ ហិកតា នៅខេត្តត្បូងឃ្មុំ បានចាប់ផ្តើមសាងសង់នៅថ្ងៃទី ២៨ ខែកុម្ភៈឆ្នាំ ២០១៩ ហើយរំពឹងថានឹងបញ្ចប់នៅខែតុលាឆ្នាំ២០២១។ មន្ទីរពេទ្យខេត្តត្បូងឃ្មុំត្រូវបានរចនាឡើងដោយក្រុមហ៊ុនចិន China IPPR International Engineering Co., Ltd ហើយបច្ចុប្បន្នកំពុងត្រូវបានសាងសង់ដោយក្រុមហ៊ុន China Railway Construction Group ដែលជាក្រុមហ៊ុនសំណង់ធំជាងគេទី២ របស់ប្រទេសចិន។ មន្ទីរពេទ្យនេះត្រូវបានសាងសង់ដោយមានសាលពិគ្រោះយោបល់វេជ្ជសាស្ត្រទូទៅ៣០០គ្រែ សម្រាប់ជំងឺទូទៅ គ្រែសម្រាក ICU ចំនួន១០ បន្ទប់ប្រតិបត្តិការ និងបន្ទប់សង្គ្រោះបន្ទាន់១ កន្លែងឱសថស្ថាន មណ្ឌលចែកចាយសារធាតុរាវ ផ្ទះបាយ និងកន្លែងតម្កល់សាកសពជាដើម។ លើសពីនេះទៀត ផ្នែកព្យាបាលដោយកាំរស្មីក៏បំពាក់ដោយម៉ាស៊ីនថតទំនើបចុងក្រោយបង្អស់ MRI, CT, DR និងម៉ាស៊ីនថតក្រពះ ពោះវៀនដ៏ទំនើបជាច្រើនទៀត។ ក្រៅពីផ្តល់ការព្យាបាលនិងសេវាសុខភាពល្អប្រសើរសម្រាប់សហគមន៍ក្បែរៗនោះ មន្ទីរពេទ្រនេះក៏នឹងបង្កើតការងារជាង៥០០ កន្លែង ដែលបម្រើជាមន្ទីរពេទ្យកណ្តាល និងជាមជ្ឈមណ្ឌលវេជ្ជសាស្ត្រដ៏ធំមួយ ដើម្បីគាំទ្រដល់តម្រូវការវេជ្ជសាស្ត្ររបស់ប្រជាជននៅភាគខាងជើងប្រទេសកម្ពុជា៕



# កម្ពុជា-ហុងកុង: ទំនាក់ទំនងពាណិជ្ជកម្មដ៏រឹងមាំជាច្រើនទសវត្សរ៍

ប្រទេសកម្ពុជានៅតែជាទីកន្លែងដ៏ល្អសម្រាប់វិនិយោគិនហុងកុងក្នុងរយៈពេល២០ឆ្នាំកន្លងមកនេះ។ ប្រទេសកម្ពុជាមានលក្ខណៈចម្រុះ មានភាពជិតស្និទ្ធ ងាយស្រួលក្នុងការធ្វើពាណិជ្ជកម្ម ឱកាសអាជីវកម្មសេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្ម កម្លាំងពលកម្មគ្រប់គ្រាន់ និងធនធាន គឺជាកត្តាទាក់ទាញវិនិយោគិនបរទេសបានយ៉ាងងាយស្រួល។



ប្រទេសកម្ពុជាបានទាក់ទាញវិនិយោគិនហុងកុងអស់រយៈពេល២០ឆ្នាំមកហើយ។

នាយកប្រតិបត្តិសមាគមពាណិជ្ជកម្មហុងកុងនៅកម្ពុជា លោក Larry Shuen Fai Ng បានឲ្យភ្នំពេញប៉ុស្តិ៍ដឹងថា៖«ហេតុផលមួយដែលពួកគេ (វិនិយោគិនហុងកុង) ចង់មកប្រទេសកម្ពុជាគឺដោយសារតែសេដ្ឋកិច្ចដែលមានដុល្លារូបនីយកម្ម គ្មានការគ្រប់គ្រងរូបិយប័ណ្ណបរទេស។ ទាំងនេះគឺពិតជាមានសារៈសំខាន់សម្រាប់ពួកគេពីព្រោះនៅហុងកុងមានអាជីវកម្មជាច្រើនក៏ប្រើប្រាស់ប្រាក់ដុល្លារអាមេរិកដែរ។

«ហេតុផលទី២គឺរដ្ឋាភិបាល បានស្វាគមន៍ជនបរទេសដ៏កក់ក្តៅដែលមកធ្វើពាណិជ្ជកម្មនៅកម្ពុជា ទោះបីថ្លៃដើមមិនទាបខ្លាំង ប៉ុន្តែយ៉ាងហោចណាស់ក៏មានភាពងាយស្រួលក្នុងការធ្វើពាណិជ្ជកម្មដែរ»។

តាមការប៉ាន់ស្មានមានវិនិយោគិនប្រមាណ២០០មកពីហុងកុង ដែលបានដាក់ទុនយ៉ាងច្រើននៅក្នុងវិស័យផលិតកម្ម សម្លៀកបំពាក់ ស្បែកជើង ចាំពេទ្យ អចលនទ្រព្យ លក់រាយ និងភោជនីយដ្ឋាន ដែលកំពុងជំរុញដល់កំណើនសេដ្ឋកិច្ចក្នុងស្រុកដូចដែលយើងអាចកត់សម្គាល់នៅក្នុងសមាជិកភាពរបស់ HKBAC។

លោកបន្ថែមថា៖«ប៉ុន្តែវិនិយោគិនកាន់តែច្រើន មកពីហុងកុងមកបើកភោជនីយដ្ឋានដើម្បីបម្រើម្ហូបបែបហុងកុង ហើយក៏មានវិនិយោគិនមកបើកហាងលក់ទំនិញផងដែរ»។

ប្រទេសកម្ពុជាដែលសេដ្ឋកិច្ចកំពុងរីកលូតលាស់យ៉ាងឆាប់រហ័ស ក៏កំពុងត្រូវការជំនាញផ្សេងៗមកពីហុងកុងផងដែរ ដូចជាផ្នែកសេវាកម្ម នៅក្នុងផ្នែករចនា ចំណេះដឹងបច្ចេកទេស អចលនទ្រព្យ និងការផ្តល់មូលនិធិសម្រាប់ក្រុមហ៊ុន ជាដើម។ លោក Ng ថ្លែងថាមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិធំៗក៏កំពុងសម្លឹងមើលបន្ថែមទៀតដើម្បីលើកទឹកចិត្តដល់ការធ្វើពាណិជ្ជកម្មរវាងហុងកុង ចិនដីគោក និងកម្ពុជា»។

ក្រុមប្រឹក្សាអភិវឌ្ឍន៍ពាណិជ្ជកម្មហុងកុង បានរៀបចំដំណើរទស្សនកិច្ចរបស់រដ្ឋាភិបាល និងសិក្ខាសាលាធុរកិច្ចដើម្បីនាំវិនិយោគិនពីហុងកុងមកកម្ពុជា ហើយសេវាកម្មមួយដែលអាចជួយជំរុញពាណិជ្ជកម្មអន្តរជាតិគឺការប្រើប្រាស់សេវាកម្មមជ្ឈត្តកម្មនៅហុងកុង ពីព្រោះយើងមានប្រព័ន្ធមជ្ឈត្តកម្ម និងប្រព័ន្ធច្បាប់ដ៏រឹងមាំស្រដៀងនឹងប្រទេសសិង្ហបុរីដែរ។

ប៉ុន្តែចំណងពាណិជ្ជកម្មដ៏រឹងមាំកំពុងរងផលប៉ះពាល់ដោយសារតែជំងឺរាតត្បាតកូវីដ១៩ ដែលបានបន្ថយល្បឿននៃការធ្វើពាណិជ្ជកម្ម និងការធ្វើដំណើររបស់វិនិយោគិន។

«មុនពេលកូវីដ យើងឃើញមានការវិនិយោគច្រើនមកពីចិនដីគោក និងហុងកុង។ ហុងកុងមានលក្ខណៈពិសេស ពីព្រោះប្រជាជនជាច្រើនក៏មានទំនាក់ទំនងជាមួយចិនដីគោកចាប់តាំងពីប្រគល់ទៅឲ្យចិនវិញ។ ក្រុមហ៊ុនហុងកុងកាន់តែច្រើន មកបណ្តាក់ទុននៅកម្ពុជាក៏មានមានទំនាក់ទំនងជិតស្និទ្ធជាមួយចិនដីគោក។

លោកបន្ថែមថា៖«តាមពិតកូវីដ១៩ មិនមែនធ្វើឲ្យវិនិយោគិនមិនចង់មកវិនិយោគនៅកម្ពុជាទេ ប៉ុន្តែវាធ្វើ ឱ្យពួកគេពិបាកធ្វើដំណើរមកកម្ពុជា។ មុនកូវីដ១៩ ក្រុមហ៊ុនអាកាសចរណ៍ Cathay Dragon ប្រតិបត្តិការជើងហោះហើរត្រង់១៤ជើងរៀងរាល់សប្តាហ៍រវាងហុងកុង និងកម្ពុជា។ ជាធម្មតានៅពេលវិនិយោគិនសម្រេចមកវិនិយោគនៅទីនេះ ពួកគេចង់មកកាន់ប្រទេសនេះ ដើម្បីស្វែងយល់អំពីប្រជាជន និងវប្បធម៌ ប៉ុន្តែដោយសារការធ្វើដំណើរត្រូវបានរឹតបន្តឹង ពួកគេមិនអាចមកកាន់ទីនេះបានទេ ដូច្នេះការវិនិយោគផ្ទាល់ពីបរទេសមានល្បឿនយឺត»៕ ■

# តម្រូវការសម្លៀកបំពាក់គេងយប់ ធ្វើឱ្យរោងចក្រ Jie Wei អាចជម្នះបញ្ហាប្រឈម

នៅពេលរោងចក្រសម្លៀកបំពាក់ Jiw Wei Cambodia Garment Factory Ltd ត្រូវបានបង្កើតនៅកម្ពុជាក្នុងឆ្នាំ២០១១ គឺដើម្បីឆ្លើយតបទៅនឹងការអំពាវនាវរបស់រដ្ឋាភិបាល ដែលជំរុញឱ្យវិនិយោគិនបរទេសជួយជំរុញដល់វិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជា។

នាយកប្រតិបត្តិក្រុមហ៊ុន JIA WEI Cambodia លោក Raymond Tam បានប្រាប់ភ្នំពេញប៉ុស្តិ៍ថា៖«១៥ឆ្នាំមុន នៅពេលដែលយើងជ្រើសរើសប្រទេសកម្ពុជាជាមូលដ្ឋានផលិតកម្មរបស់យើង ថ្លៃដើមនៃការផលិតសម្លៀកបំពាក់នៅលើទីផ្សារក្នុងស្រុកដូចជាប្រាក់ឈ្នួល ទីតាំងរោងចក្រ និងការដឹកជញ្ជូននៅមានកម្រិតទាប ហើយអ្វីដែលគួរឱ្យទាក់ទាញសម្រាប់យើងមកវិនិយោគនៅកម្ពុជា គឺដោយសាររដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដារ ខណៈប្រទេសនេះបាននាំចេញទៅកាន់ទីផ្សារជាច្រើននៅជុំវិញពិភពលោក។



លោក So Man Kit និងលោក Raymond Tam ពេលផ្តល់បទសម្ភាសជាមួយភ្នំពេញប៉ុស្តិ៍។

ដោយចូលរួមនៅក្នុងឧស្សាហកម្មផលិតសម្លៀកបំពាក់នៅកម្ពុជាអស់រយៈពេលជាង១ទសវត្សរ៍កន្លងមកនេះ លោក Raymond ដែលក៏ជានាយកសមាគមពាណិជ្ជកម្មហុងកុងនៅកម្ពុជា ( HKBAC ) និងជាសមាជិកគណៈកម្មការប្រតិបត្តិនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ( GMAC )ផងដែរនោះបានឃើញឧស្សាហកម្មមួយនេះមានការវិវត្តខ្លាំងជាពិសេសនៅក្នុងពេលបច្ចុប្បន្ន។

«នៅពេលយើងចាប់ផ្តើមផលិតនៅកម្ពុជា ក្នុងឆ្នាំ២០១១ យើងបានចាប់ផ្តើមពីរោងចក្រតូចមួយ និងមានកម្លាំងពលកម្មតិច»។

ប៉ុន្តែសព្វថ្ងៃ យើងមានរោងចក្រធំមួយនៅផ្លូវវែងស្រែង រាជធានីភ្នំពេញ និងមានក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលមានទីតាំងនៅក្បែរនោះ ដែលមានបុគ្គលិកជាង ១ ២០០ នាក់ រួមទាំងបុគ្គលិកផ្នែកគ្រប់គ្រងផងដែរ»។

អស់រយៈពេលជាច្រើនឆ្នាំ JIE WEI បានផលិត និងនាំចេញសម្លៀកបំពាក់ប្រមាណ១០លានខោអាវ ទៅសហភាពអឺរ៉ុប (EU) ជារៀងរាល់ឆ្នាំ។

ទោះយ៉ាងណា ជាមួយនឹងការរីករាលដាលនៃជំងឺកូវីដ១៩ នៅដើមឆ្នាំ២០២០នេះ និងសហភាពអឺរ៉ុបបានដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធ (EBA) ពីកម្ពុជា កាលពីខែសីហា ក្រុមហ៊ុនត្រូវពិនិត្យមើលទីផ្សារថ្មីជំនួស និងវិធីសាស្ត្រថ្មីៗក្នុងការធ្វើអាជីវកម្មដើម្បីទ្រទ្រង់ប្រតិបត្តិការរបស់ខ្លួនឱ្យមានការប្រកួតប្រជែង។

ជាភ័ព្វសំណាងសម្រាប់ JIE WEI វិធីសាស្ត្រធ្វើពិពិធកម្មរបស់ពួកគេទៅក្នុងទីផ្សារអាមេរិក និងកាណាដាទទួលបានភាគលាភល្អ។

តើអ្នកណាដែលគិតដល់ថាជំងឺកូវីដ-១៩ បានធ្វើឱ្យក្រុមហ៊ុនរអាជីវកម្មរបស់យើងនៅតែមានអ្នកត្រូវការ ជាពិសេសនៅពេលមានភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចបែបនេះ ?

«ទោះជឿ ឬមិនជឿ ការផលិតខោអាវគេង បានជួយឱ្យអាជីវកម្មរបស់យើងនៅដំណើរការធម្មតា។ ក្នុងអំឡុងពេលនៃការរីករាលជំងឺកូវីដ១៩ ប្រជាជនភាគច្រើនបានស្នាក់នៅក្នុងផ្ទះ ហើយតម្រូវការខោអាវគេងបានកើនឡើងជាលំដាប់។

លោក Raymond មានប្រសាសន៍ថា៖«ជាលទ្ធផល អ្នកបញ្ជាទិញផ្ទាល់ពីយើងគឺមានហាង Target និង Walmart ដែលបានស្នើសុំឱ្យយើងផលិត និងនាំចេញនូវខោអាវគេងយប់នៅក្នុងបរិមាណដ៏ច្រើនសម្រាប់ទីផ្សារសហរដ្ឋអាមេរិក និងរហូតដល់ទីផ្សារកាណាដា»។

ចំពោះបញ្ហាប្រឈមដែលសហភាពអឺរ៉ុបដក EBA ផ្នែកខ្លះពីកម្ពុជា សម្រាប់ លោក Raymond មានទំនុកចិត្តថាជាមួយនឹងកិច្ចខិតខំប្រឹងប្រែង និងមានផែនការធ្វើពិពិធកម្មអាជីវកម្មទៅក្នុងទីផ្សារដែលចំណេញច្រើន ហើយ នៅពេលអនាគត JIE WEI អាចនឹងពឹងផ្អែកតិចទៅលើទីផ្សារអឺរ៉ុប។

លោកបានបន្ថែមថា៖«ការព្រួយបារម្ភចម្បងសម្រាប់យើងជាមួយទីផ្សារអឺរ៉ុប គឺចាប់ពីខែសីហា ឆ្នាំ២០២០ ពន្ធនាំចូលនឹងត្រូវអនុវត្តលើ៤០ប្រភេទ គឺ២៥ប្រភេទសម្រាប់សម្លៀកបំពាក់ ៩ប្រភេទសម្រាប់ស្បែកជើង និង ៦ប្រភេទសម្រាប់កាបូប។ ជាមួយនឹងការយកពន្ធលើការបញ្ជាទិញ នឹងធ្វើឱ្យការនាំចេញរបស់យើងថយចុះ។

«ការកាត់បន្ថយចំណាយប្រតិបត្តិការ អាចជាជម្រើសមួយផ្សេងទៀតដែលយើងអាចពិចារណាប្រសិនបើយើង មានគម្រោងផ្តោតជាថ្មីម្តងទៀតនៅលើទីផ្សារអឺរ៉ុប ប៉ុន្តែសម្រាប់ពេលនេះ យើងក៏នឹងស្វែងរកដំណោះស្រាយ និងឱកាសផ្សេងទៀតដែលអាចកាត់បន្ថយការបាត់បង់សក្តានុពលនៅទីផ្សារសហភាពអឺរ៉ុប»។

ទោះយ៉ាងណាក៏ដោយ សម្រាប់ JIE WEI ការផលិតសម្លៀកបំពាក់សម្រាប់គេងយប់ ច្បាស់ណាស់រងផលប៉ះពាល់ ស្របពេលដែលមានភាពមិនប្រាកដនៃឧស្សាហកម្មកាត់ដេរនៅទូទាំងពិភពលោក៕ ■

# បន្ទាប់ពីអាជីវកម្មបានធ្លាក់ចុះ ក្រុមហ៊ុន Ming Fai Group ជឿជាក់ថានឹងមានសម្ទុះងើបឡើងវិញ


**ក្រុមហ៊ុន** Ming Fai Enterprise ( Cambodia ) Co Ltd **បច្ចុប្បន្នមាន១៦រោងចក្រ។**


**លោក** Ching Chi Fai ។

ក្រុមហ៊ុនដែលបានចុះបញ្ជីនៅហុងកុង Ming Fai Group គឺជាក្រុមហ៊ុនអន្តរជាតិដែលមានឯកទេសខាងផលិតសម្ភារប្រើប្រាស់នៅក្នុងសណ្ឋាគារ និងលើយន្តហោះ បានជ្រើសរើសប្រទេសកម្ពុជាជាមជ្ឈមណ្ឌលផលិតកម្មដ៏សំខាន់របស់ខ្លួននៅក្នុងតំបន់ ដោយសារតែគោលនយោបាយធុរកិច្ចដ៏ទាក់ទាញរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺ Ming Fai Enterprise ( Cambodia )Co Ltd បានចាប់ផ្ដើមប្រតិបត្តិការនៅកម្ពុជាក្នុងឆ្នាំ២០១៨ បច្ចុប្បន្នបានដំណើរការរោងចក្រចំនួន១៧ និងមានកម្មករបម្រើការងារជាង ២ ០០០នាក់អំឡុងពេលប្រតិបត្តិការដល់ចំណុចខ្ពស់បំផុត ហើយគោលដៅនាំចេញភាគច្រើនគឺទីផ្សារអាមេរិក និងអឺរ៉ុប។

ក្រុមហ៊ុនផលិតនូវផលិតផលជាច្រើនប្រភេទ ដូចជា សម្ភារប្រើប្រាស់ក្នុងសណ្ឋាគារ ស្បែកជើងប្រើក្នុងសណ្ឋាគារ ម៉ាស់បាំងភ្នែកសម្រាប់ដេក ស្រោមជើង ថង់ពាក់ក្បាលសម្រាប់ពេលងូតទឹក កាបូប កញ្ចប់ធ្វើដំណើរ និងសម្ភារជាច្រើនមុខទៀត។ ផលិតផលទាំងនេះគឺសម្រាប់ប្រើប្រាស់ក្នុងសណ្ឋាគារ និងនៅក្នុងឧស្សាហកម្មអាកាសចរណ៍។

ប៉ុន្តែក្រុមហ៊ុនផ្គត់ផ្គង់ផលិតផលនេះ ក៏បានរងផលប៉ះពាល់ដោយសារការផ្ទុះឡើងជំងឺកូវីដ១៩ដែរ ខណៈតម្រូវការបានធ្លាក់ចុះ ហើយដំណើរការខ្សែចង្វាក់ផលិតកម្មត្រូវបានកាត់បន្ថយ។ ទោះបីជាយ៉ាងណា ប្រធាន និងជានាយកប្រតិបត្តិក្រុមហ៊ុន Ming Fai Group លោក Ching Chi Fai មានទំនុកចិត្តថា អាជីវកម្ម នឹងងើបឡើងវិញ ខណៈវិស័យផលិតកម្មរបស់ប្រទេសកម្ពុជានឹងងើបឡើងវិញបន្ទាប់ពីធ្លាក់ចុះដោយសារការផ្ទុះឡើងជំងឺកូវីដ១៩។

«ប្រតិបត្តិការអាជីវកម្មរបស់យើងរងផលប៉ះពាល់យ៉ាងខ្លាំង ពីជំងឺរាតត្បាតមួយនេះ។ ក្នុងអំឡុងពេលនោះកម្លាំងពលកម្មរបស់យើងត្រូវបានកាត់បន្ថយមកនៅត្រឹម៧០០នាក់ ដោយសារតែការបញ្ជាទិញពីអតិថិជនរបស់យើងមានការធ្លាក់ចុះយ៉ាងខ្លាំង។ គិតត្រឹមខែកញ្ញាចំនួនកម្មករសកម្មរបស់យើងមានប្រមាណ១ ២០០នាក់»។

«តម្រូវការផលិតផលរបស់យើងភាគច្រើនមានប្រភពចេញពីឧស្សាហកម្មទេសចរណ៍ ដែលប៉ុន្មានឆ្នាំថ្មីៗនេះមានកំណើនថេរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មុនពេលមានជំងឺរាតត្បាតនេះផ្ទុះឡើង។ ខ្ញុំជឿថា ក្នុងរយៈពេល៥ឆ្នាំ ឧស្សាហកម្មទេសចរណ៍នៅអាស៊ីអាគ្នេយ៍នឹងងើបឡើងវិញ និងមានកំណើនដ៏រឹងមាំ»។

លោកថ្លែងថា៖«យើងក៏កំពុងខិតខំពង្រីកអាជីវកម្មរបស់យើងនៅក្នុងប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍»។

ក្រុមហ៊ុន Ming Fai មានមូលដ្ឋានផលិតកម្មចំនួន៥ ហើយមជ្ឈមណ្ឌលប្រតិបត្តិការរបស់ខ្លួនស្ថិតនៅក្នុងទីក្រុង Shenzhen ក្នុងប្រទេសចិន និងទីតាំងផ្សេងទៀតមាននៅប្រទេសកម្ពុជា និងឥណ្ឌា។

លោក Ching បន្ថែមថា ចាប់តាំងពីជំងឺនេះផ្ទុះឡើង ការបញ្ជាទិញពីទីផ្សារអាមេរិក និងអឺរ៉ុបបានធ្លាក់ចុះយ៉ាងខ្លាំង ខណៈតម្រូវការពីទីផ្សារចិនបានចាប់ផ្ដើមកើនឡើង។ «ជាមួយនឹងការបញ្ជាទិញកើនឡើងបន្តិចម្ដងៗ ដើម្បីដល់កម្រិត មុនជំងឺរាតត្បាតនេះផ្ទុះឡើង ចំនួនកម្មករសកម្មនឹងកើនឡើងដល់ចំនួនចាស់ គឺ ២ ០០០នាក់នៅចុងឆ្នាំនេះ។

ទោះបីប្រាក់ចំណូលថយចុះ ក្រុមហ៊ុន Ming Fai នៅតែផ្ដល់ប្រាក់ឧបត្ថម្ភពិសេសដល់កម្មករដែលត្រូវបានបញ្ឈប់ជាបណ្ដោះអាសន្នតាមការតម្រូវរបស់រដ្ឋាភិបាលកម្ពុជា។

លោកមានប្រសាសន៍ថា ការរីករាលដាលនៃជំងឺកូវីដ១៩ដែលមិនធ្លាប់មានពីមុននេះ បានគំរាមកំហែងដល់ទីផ្សារសកល និងអស្ថិរភាពភូមិសាស្ត្រនយោបាយ អាចបង្កផលប៉ះពាល់រយៈពេលមធ្យមដល់ប្រតិបត្តិការផលិតកម្មរបស់ក្រុមហ៊ុន Ming Fai Group។

«ប៉ុន្តែ ខ្ញុំជឿជាក់ថា ក្រុមហ៊ុនជាច្រើនក៏នឹងធ្វើការកែតម្រូវឲ្យស្របតាមកាលៈទេសៈផ្ទាល់ខ្លួន ដើម្បីទទួលបានការអភិវឌ្ឍឲ្យកាន់តែប្រសើរសម្រាប់ពេលអនាគត»៕ ■



# WMC មានសុទិដ្ឋិនិយមខ្ពស់ ខណៈការលក់រថយន្តចិនកំពុងមានកំណើន

ខណៈក្រុមហ៊ុន Worldwide Motors Company Ltd (WMC) ចូលរួមអបអរសាទរខួបអនុស្សាវរីយ៍នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី១ ខែតុលានេះ ក្រុមហ៊ុនលក់រថយន្តចិនឈានមុខគេនៅកម្ពុជា មានសារដ៏រីវិជ្ជមាននៅក្នុងឱកាសដ៏ពិសេសនេះ។

ក្រុមហ៊ុន WMC មានសុទិដ្ឋិនិយមខ្ពស់ចំពោះបេសកកម្មរបស់ខ្លួន ក្នុងការនាំមកនូវរថយន្តចិនគុណភាពខ្ពស់ដល់ប្រជាជនកម្ពុជាដែលចង់បានរថយន្តថ្មីផ្ទាល់ខ្លួន។

«ភាពជោគជ័យជាបន្តបន្ទាប់របស់ក្រុមហ៊ុន WMC និងការកើនឡើងនូវប្រជាប្រិយភាពរថយន្តចិនគឺមានចំណែកដ៏ធំមួយនៅក្នុងភាពជាដៃគូរវាងចិន និងកម្ពុជា»។

លោក Alex Cheong ប្រធានផ្នែកលក់ជាន់ខ្ពស់បានថ្លែងថា៖«នៅពេលដែលអតិថិជនកម្ពុជាមកមើលរថយន្តនិងបានឃើញពីគុណភាពដ៏ល្អនៃរថយន្តចិនដែលយើងលក់ ពួកគេពិតជាចាប់អារម្មណ៍ខ្លាំង។ គុណភាពនៃការផលិតរថយន្តរបស់ចិនបច្ចុប្បន្នគឺដូចគ្នាទៅនឹងរថយន្តជប៉ុន អឺរ៉ុប និងសហរដ្ឋអាមេរិកដែរ។

ការផ្លាស់ប្តូរការយល់ឃើញនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្រុមហ៊ុន WMC ក្នុងឆ្នាំនេះ តាមរយៈការពង្រីកអគារតាំងបង្ហាញរថយន្តនៅក្នុងរាជធានីភ្នំពេញរហូតដល់៤កន្លែង ខណៈចំនួនលក់រថយន្តកំពុងមានសម្ទុះកើនឡើង។

«យើងមានអគារតាំងបង្ហាញរថយន្តថ្មី២ទៀតនៅដើមឆ្នាំនេះ ខណៈយើងដឹងថា ប្រជាជនកម្ពុជាកាន់តែច្រើនយល់កាន់តែច្បាស់ថារថយន្តចិនគឺមានគុណភាពខ្ពស់ដូចរថយន្តផ្សេងទៀតដែលមាននៅលើទីផ្សារដែរ ជាពិសេសមានតម្លៃធូរថ្លៃ ប៉ុន្តែមានគុណភាពដូចគ្នា»។

«ចំណុចនេះគួបផ្សំនឹងការយកចិត្តទុកដាក់របស់យើងចំពោះចំណាប់អារម្មណ៍របស់អតិថិជនដើម្បីផ្តល់ឲ្យពួកគេនូវសេវាកម្មដ៏ល្អដែលធ្វើឱ្យ WMC ក្លាយជាទិសដៅដ៏ស័ក្តិសមបំផុតសម្រាប់អ្នកដែលមានបំណងចង់ទិញរថយន្តថ្មី»។

«យើងមានមោទនភាពចំពោះការផ្តល់ជូននេះ។ យើងមានក្រុមការងារ២៤ម៉ោងក្នុង១ថ្ងៃ ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ឧទាហរណ៍ខ្ញុំតែងតែទូរស័ព្ទទៅអតិថិជនរៀងរាល់សប្តាហ៍ដើម្បីធ្វើឲ្យប្រាកដថាពួកគេរីករាយ»។



ក្រុមហ៊ុន WMC មានអគារតាំងបង្ហាញរថយន្តចំនួន៤នៅក្នុងរាជធានីភ្នំពេញ។

លោក Cheong ថ្លែងថា៖«ដូច្នេះអតិថិជនកាន់តែច្រើនកំពុងជ្រើសរើសទិញរថយន្តចិនថ្មីពីក្រុមហ៊ុនរបស់យើង ហើយក្នុពេលឆាប់ៗយើងរំពឹងថា ការលក់របស់យើងនឹងកើនឡើងទ្វេដង ឬ៣ដង»។

ក្រុមហ៊ុន WMC មានលក់រថយន្តរបស់ចិនម៉ាកល្បីៗជាច្រើនដូចជា Haval, Bestune, Huanghai, FAW និង Zotye ជាដើម និងមានម៉ូដែលសម្រាប់បម្រើដល់គ្រប់ផ្នែកក្នុងសង្គមដែលមានតម្លៃចាប់ពី ២៥ ០០០ ទៅ ៧៥ ០០០ដុល្លារ។

លោក Cheong បន្តថា៖«យើងមានរថយន្តប្រភេទ SUV និងភិកអាប់គ្រប់ប្រភេទសម្រាប់គ្រប់តម្រូវការដូចរថយន្តម៉ាក FAW ជាដើម។ រថយន្តម៉ាក Haval H6 និង H9 រួមជាមួយ Bestune និង Huanghai ស្ថិតនៅក្នុងចំណោមរថយន្តដែលលក់ដាច់ជាងគេបំផុតរបស់យើង»។

ដោយគ្រាន់តែមានប្រាក់នៅក្នុងដៃត្រឹមពី១៥ ទៅ២០ភាគរយនៃតម្លៃរថយន្ត នោះគាត់ក៏អាចក្លាយជាម្ចាស់រថយន្តថ្មីបានដែរ។ គួបផ្សំជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ដោយមានសេវាកម្មប្រចាំឆ្នាំដោយឥតគិតថ្លៃសម្រាប់រយៈពេលនៃការបង់ប្រាក់ និងការធានាចាប់ពី៥ ទៅ៧ឆ្នាំនិងការធានាផ្នែកគ្រឿងបន្លាស់ចន្លោះពី៥ ទៅ១០ឆ្នាំ។ លោក Cheong ថ្លែងថា ការទិញរថយន្តថ្មីគឺផ្តល់អត្ថប្រយោជន៍ច្រើន និងមានសុវត្ថិភាពខ្ពស់»។

ជាមួយនឹងការផ្តល់ជូនជាកញ្ចប់ពេញលេញបែបនេះលោក Cheong ថ្លែងថា រថយន្តចិននឹងក្លាយជារថយន្តដែលនឹងត្រូវបានគេមើលឃើញធ្វើចរាចរណ៍កាន់តែច្រើននៅតាមដងផ្លូវនានាក្នុងប្រទេសកម្ពុជា។

«សាររបស់យើងគឺថាជាមួយនឹងរថយន្តចិនដែលមានគុណភាពខ្ពស់ និងការយកចិត្តទុកដាក់ខ្ពស់បន្ទាប់ពីការលក់ និងការយកចិត្តទុកដាក់របស់អតិថិជនក៏ដូចជាជម្រើសបង់ប្រាក់ ធ្វើឱ្យលោកអ្នកក្លាយជាម្ចាស់រថយន្តថ្មីបាន ហើយក្រុមហ៊ុន WMC គឺជាជម្រើសដ៏ពិតប្រាកដសម្រាប់អ្នកទិញរថយន្តនៅកម្ពុជា»។

លោក Cheong បានបន្ថែមថា៖ «សូមទៅកាន់អគារតាំងបង្ហាញណាមួយក្នុងចំណោមអគារតាំងបង្ហាញទាំង៤ របស់យើង នោះលោកអ្នកនឹងឃើញរថយន្តថ្មីដ៏ប្រណីតគួរជាទីគាប់ចិត្ត»៕ ■



# កម្ពុជា បង្កើនការនាំចេញចេកអំបូងលឿងទៅកាន់ទីផ្សារចិនទោះបីមានវិបត្តិកូវីដ១៩

ទោះបីជាមានបញ្ហាសេដ្ឋកិច្ច និងការធ្វើពាណិជ្ជកម្មធ្លាក់ចុះនៅតាមតំបន់ខ្លះនៃពិភពលោកដោយសារ Covid-19 ក៏ដោយ ក៏អ្នកដាំចេកនៅកម្ពុជាកំពុងរីករាយនឹងជំនួញនេះ ដោយបង្កើនការនាំចេញចេកយ៉ាងលឿន បើទោះបីជាមានការលំបាកមួយចំនួនក្តី។



បច្ចុប្បន្នមានក្រុមហ៊ុនដាំចេកប្រមាណ២០នៅកម្ពុជាដើម្បីនាំចេញទៅប្រទេសចិន។

ក្រុមហ៊ុនផ្លែឈើក្នុងស្រុក Tropicam ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធបានសហការជាមួយក្រុមហ៊ុនចិន Longmate Agriculture Co Ltd, កំពុងមានភាពមមាញឹកក្នុងការនាំចេញចេកអំបូងលឿងទៅកាន់ប្រទេសចិនដែលជាទីផ្សារដ៏ធំ។

អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ គឺតម្រូវការចេកអំបូងលឿងរបស់កម្ពុជាបានកើនឡើងលើសការរំពឹងទុកចាប់តាំងពីពាក់កណ្តាលឆ្នាំ ២០១៨ ។

លោក ឡោ ងី នាយកប្រតិបត្តិក្រុមហ៊ុន Tropicam បានថ្លែងប្រាប់ភ្នំពេញប៉ុស្តិ៍ថា បច្ចុប្បន្ន ក្រុមហ៊ុនរបស់ខ្លួនបន្តដំណើរការធម្មតាដោយបាននាំចេញផ្លែចេកអំបូងលឿងទៅកាន់ទីក្រុងស៊ាងហៃ ក្រុងស៊ិនជិន និងបណ្តាលខេត្តមួយចំនួននៃប្រទេសចិន។ លោកថា៖«តាមពិតទៅអំឡុងពេលកូវីដ ក្រុមហ៊ុននៅបន្តដំណើរការធម្មតា ហើយអាចនិយាយបានថាល្អជាងមុន ព្រោះក្រុមហ៊ុនយើងជាប្រភេទផ្លែឈើហូប អ៊ីចឹងនៅពេលកូវីដ សម្ទុះនៃការហូបចុកនៅចិនមានការកើនឡើង ពីមុនយើងនាំចេញផ្លែចេក ២៥០ តោនក្នុង១សប្តាហ៍ តែអំឡុងពេលកូវីដ យើងនាំចេញ៣០០តោន ក្នុង១សប្តាហ៍»។

បើតាមលោក ឡោ ងី ផ្លែចេកមានតម្រូវការទីផ្សារខ្ពស់នៅប្រទេសចិន ដោយសារ ផ្លែចេកគឺជាអាហារចម្បងដែលជនជាតិចិនចូលចិត្តបរិភោគ។ លោកថា៖«ខ្ញុំសង្កេតឃើញថាទីផ្សារចិនល្អ កាលពីឆ្នាំ២០១៨ មានតែ៥ក្រុមហ៊ុនដែលបាននាំចេកទៅប្រទេសចិន ប៉ុន្តែបច្ចុប្បន្នមានទៅដល់ ២០ក្រុមហ៊ុន ដែលបានចុះបញ្ជី ព្រោះមានអ្នកវិនិយោគិនចិន សហការជាមួយខ្មែរ ក្នុងការដាំដុះ និងនាំចេញផ្លែចេកទៅប្រទេសចិន។

តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានឱ្យដឹងថា ប្រទេសកម្ពុជាបាននាំចេញចេកអំបូងលឿងស្រស់ចំនួន ៧២, ១៨២តោនទៅកាន់ទីផ្សារអន្តរជាតិក្នុងអំឡុងពេល ៣ខែដំបូងនៃឆ្នាំ ២០២០ ខណៈកាលពីឆ្នាំ២០១៩ បាននាំចេញចេកអំបូងលឿងសរុបចំនួន ១៥៧.៨១២តោនហើយជាមធ្យម ប្រទេសនេះបាននាំចេញចេកច្រើនជាង ៧៩៥តោនក្នុង១ថ្ងៃ។ ចេកអំបូងលឿងភាគច្រើនត្រូវបាននាំចេញទៅប្រទេសចិន ក្រៅពីនោះត្រូវបាននាំចេញទៅកាន់ប្រទេសវៀតណាម និងជប៉ុន។

កម្ពុជាមានអាកាសធាតុត្រូពិកត្រជាក់ ហើយសើម និងមានភ្លៀងធ្លាក់ខ្លាំងផ្តល់អំណោយផលសម្រាប់ការដាំដុះចេកពេញ១ឆ្នាំ។ នៅឆ្នាំ ២០១៨ ក្រុមហ៊ុន Longmate បានប្រកាសថា នឹងវិនិយោគទឹកប្រាក់ ៣២លានដុល្លារ ដើម្បីដាំដំណាំលើផ្ទៃដីប្រមាណ ១០០០ហិកតានៅស្រុកឈូក ខេត្តកំពត។

លោក ឡោ ងី ឱ្យដឹងដែរថា ក្រុមហ៊ុនបាននាំពូជចេកអំបូងលឿងពីប្រទេសអូស្ត្រាលី មកដាំនៅស្រុកខ្មែរ ដោយសារដីមានជីវជាតិ ផ្ទៃដីដាំដុះធំ និងមានអាកាសធាតុល្អ។ «ព្រោះចេកត្រូវការទឹកច្រើន ត្រូវនឹងអាកាសធាតុនៅកម្ពុជា ជាពិសេសក្នុងខេត្តកំពត ព្រោះចេកដាំអត់សូវបានទេបើនៅចិន ដោយសារតំបន់ខ្លះត្រជាក់ពេក ហើយតំបន់ខ្លះក្តៅពេក ដូច្នេះបានជាមានអ្នកវិនិយោគក្រៅប្រទេសជាច្រើនបានមកវិនិយោគដាំចេកនៅកម្ពុជា ដើម្បីនាំចេញទៅទីផ្សារខាងក្រៅ»។

ក្រៅពីការនាំចេញផ្លែចេក ក្រុមហ៊ុន Tropicam ក៏គ្រោងនឹងបន្ថែមការនាំចេញផ្លែឈើ១ប្រភេទទៀត គឺផ្លែស្វាយកែវរមៀត នៅចុងឆ្នាំ ២០២០។ លោកថា «យើងមានចម្ការស្វាយខ្លួនឯងខ្លះ និងបានសហការជាមួយសហគមន៍ ដើម្បីប្រមូលទិញស្វាយ និងត្រៀមនាំចេញទៅទីផ្សារប្រទេសចិន នៅចន្លោះខែតុលា ២០២០ នេះ ប៉ុន្តែយើងនាំចេញដោយឆ្លងកាត់ច្រកព្រំដែនវៀតណាម ដោយរំពឹងថា នឹងនាំចេញផ្លែស្វាយឱ្យបាន ១០០តោនក្នុង ១ថ្ងៃផងដែរ»។

ជាមួយនឹងការនាំចេញនេះដែរ លោកឡោងីសម្តែងអារម្មណ៍ថា «យើងមានមោទនភាពដែលអាចនាំចេញដំណាំកសិកម្មទៅក្រៅប្រទេស រួមចំណែកជួយដល់សេដ្ឋកិច្ចជាតិ គឺរដ្ឋាភិបាលរកចំណូលតាមរយៈការប្រមូលពន្ធ យើងផ្តល់ការងារដល់កសិករជាង ៨០០នាក់ សម្រាប់ថែទាំចម្ការ ហើយអាចកាត់បន្ថយការធ្វើចំណាកស្រុកបានទៀតផង»៕ ■



# Urban Village ចូលរួមប្រជែង "ពានរង្វាន់ក្រុមហ៊ុនអភិវឌ្ឍន៍ខុនដូល្អបំផុតនៅអាស៊ី"

ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យ Urban Hub Cambodia Co Ltd ដែលកំពុងចាប់ផ្តើមគម្រោងខុនដូទី៣របស់ខ្លួន គឺសាងសង់អគារខុនដូដែលមានគុណភាព និងផាសុកភាពខ្ពស់ ដោយប្តេជ្ញារក្សាកេរ្តិ៍ឈ្មោះរបស់ខ្លួនក្នុងនាមជាក្រុមហ៊ុនសាងសង់លំដាប់កំពូល។

ប្រធាន និងជាស្ថាបនិកក្រុមហ៊ុន Urban Village លោក Ben Li បានចែករំលែកទស្សនវិស័យរបស់ក្រុមហ៊ុនដូចខាងក្រោម។

**១) នៅក្នុងកម្មវិធីប្រគល់ពានរង្វាន់អចលនទ្រព្យប្រចាំឆ្នាំ** PropertyGuru Cambodia Property Awards **លើកទី៥ ក្រុមហ៊ុន** Urban Hub **បានឈ្នះពានរង្វាន់ជាច្រើន។ តើលោកអាចប្រាប់យើងបន្ថែមអំពីសមិទ្ធផលទាំងនេះបានទេ?**

Urban Village បានឈ្នះពានរង្វាន់ច្រើនជាងគេនៅក្នុងកម្មវិធីប្រគល់ពានរង្វាន់អចលនទ្រព្យ PropertyGuru Property Awards ។ យើងបានឈ្នះពានរង្វាន់ចំនួន១៣ ក្នុងរយៈពេលសរុប២ឆ្នាំ។ ក្នុងឆ្នាំនេះ យើងបានឈ្នះពានរង្វាន់ចំនួន៧ ហើយជាថ្មីម្តងទៀតយើងបានឈ្នះពានរង្វាន់«Best Condo Development in Cambodia» ពានរង្វាន់« Best Condo Development in Phnom Penh » និងពានរង្វាន់ផ្សេងទៀតរួមមាន« Best Breakthrough Developer» ពានរង្វាន់ « Best Co-Working Space » ពានរង្វាន់« Best Office Development» ពានរង្វាន់ « Best Office Architectural Design » និងពានរង្វាន់« Best Lifestyle Developer»។

យើងចង់ប្រាប់ពិភពលោកថា ប្រទេសកម្ពុជាគឺជាចំណុចវិនិយោគដ៏ទាក់ទាញ១ដែលមានគោលនយោបាយបើកចំហ និងការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណដែលមានមុខងារ និងគ្មានការរឹតត្បិតចំពោះការផ្ទេរប្រាក់ទៅប្រទេសផ្សេងដូចជាប្រទេសសិង្ហបុរីជាដើម។

**២) នេះមិនមែនជាលើកទី១ទេដែល** Urban Hub **បានទទួលពានរង្វាន់ច្រើនបែបនេះ។ តើអ្វីជំរុញក្រុមហ៊ុនរបស់លោកឱ្យរក្សាបាននូវភាពលេចធ្លោក្នុងវិស័យអចលនទ្រព្យនៅកម្ពុជាបែបនេះ?**



**គម្រោង** Urban Village **ដំណាក់កាលទី១ ក្នុងរាជធានីភ្នំពេញ។**

Urban Village មិនមែនគ្រាន់តែជាសំណង់បេតុងប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលយើងកំពុងសាងសង់នៅទីនេះ គឺមិនមាននៅកន្លែងផ្សេងទេនៅក្នុងប្រទេសកម្ពុជា។ គម្រោង Urban Village គឺនៅជាប់នឹងមជ្ឈមណ្ឌល Factory Phnom Penh ដែលជាមជ្ឈមណ្ឌលច្នៃប្រឌិតធំបំផុតនៅអាស៊ីអាគ្នេយ៍។

Urban Village មិនមែនគិតតែពីប្រាក់ចំណេញនោះទេ ផ្ទុយទៅវិញ យើងមានបេសកកម្មផ្តល់សហគមន៍១ដល់ប្រជាជនកម្ពុជាជំនាន់ថ្មី។

យើងកំពុងផ្តោតលើការកសាងសហគមន៍១ដែលគិតពីការពេញចិត្ត និងបទពិសោធរបស់អ្នករស់នៅ។ រាល់ការរចនានៃគម្រោងរបស់យើង គឺធ្វើឱ្យប្រាកដថាអ្នករស់នៅក្នុងគម្រោងរបស់យើងនឹងមានបទពិសោធនៃការរស់នៅស្តង់ដាអន្តរជាតិល្អបំផុត ហើយខ្ញុំគិតថា នេះជាចំណុចដែលធ្វើឱ្យយើងលេចធ្លោនៅក្នុងឧស្សាហកម្មអចលនទ្រព្យនៅកម្ពុជា។

**៣) សូមលោកសង្ខេបអំពីគម្រោងដែលកំពុងដំណើរការ និងស្ថានភាពបច្ចុប្បន្ន**

Urban Village ដំណាក់កាលទី២ គឺជាគម្រោងទី៣របស់យើងនៅកម្ពុជា។ ទី១ គឺ Urban Loft ដែលត្រូវបានបញ្ចប់ និងប្រគល់ជូនឱ្យម្ចាស់រួចហើយ ហើយអ្នកជួលបច្ចុប្បន្នកំពុងរស់នៅទីនោះដោយភាពសប្បាយរីករាយ។

គម្រោងទី២របស់យើងគឺ Urban Village ដំណាក់កាលទី១ ដែលត្រូវបានបញ្ចប់ និងប្រគល់ទៅឱ្យម្ចាស់។ យើងគឺជាក្រុមហ៊ុនអភិវឌ្ឍន៍ដែលមានការប្តេជ្ញាចិត្តខ្ពស់ យើងអនុវត្តគម្រោងបានទាន់ពេលវេលា សូម្បីតែក្នុងអំឡុងពេលជំងឺកូវីដ១៩។

ពេលនេះយើងកំពុងធ្វើគម្រោងទី៣របស់យើងគឺ Urban Village ដំណាក់កាលទី២។ បច្ចុប្បន្នការបុកគ្រឹះកំពុងដំណើរការ ហើយគ្រឹះ ៤៥០ដើម ក្នុងចំណោម ៥៤០ដើម ត្រូវបានបញ្ចប់។ ការប្រគល់សម្រាប់ដំណាក់កាលទី២ គ្រោងនឹងធ្វើនៅខែមិថុនា ឆ្នាំ២០២៣។

យើងផ្តោតលើការរស់នៅរបស់ប្រជាជនកម្ពុជាជំនាន់ថ្មី ដែលមានប្រជាជនកម្ពុជាជាង៧០ភាគរយរស់នៅក្នុងគម្រោងរបស់យើង គឺមានសារៈសំខាន់ខ្លាំងណាស់៕ ■



# វិស័យកាត់ដេរត្រៀមខ្លួនដើម្បីផលិតទំនិញលំដាប់ខ្ពស់សម្រាប់ទីផ្សារពិភពលោក

លោក Lin Zhi Qiang នាយកក្រុមហ៊ុន Q-Port Investments (Cambodia) Co Ltd ថ្លែងថា ឧស្សាហកម្មកាត់ដេរនៅកម្ពុជាគួរតែផ្លាស់ប្ដូរធ្វើឱ្យមានលក្ខណៈចម្រុះដោយសន្សឹមៗងាកទៅផលិតសម្លៀកបំពាក់ដែលមានតម្លៃមធ្យម និងការលក់រាយ ។

ក្រុមហ៊ុន Q-Port Investments គឺជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃក្រុមហ៊ុន E-Port Enterprise (HK) Co Ltd ដែលមានមូលដ្ឋាននៅហុងកុង ។ សហគ្រាសកាត់ដេរ ផលិតសម្លៀកបំពាក់ម៉ាក E-Port, ការបង្កើតមូលដ្ឋានផលិតកម្មរបស់ខ្លួននៅកម្ពុជាតាមរយៈក្រុមហ៊ុន Q-Port Investments, Q-Port Enterprise ផលិត និងនាំចេញនូវផលិតផលជាបន្តបន្ទាប់ទៅអឺរ៉ុប អាមេរិក ជប៉ុន និងកាណាដា។

Q-Port Investments បានប្រតិបត្តិការរោងចក្រកាត់ដេរចំនួន ២ និងកន្លែងបោកគក់គំរូមួយ ដែលបម្រើដល់រោងចក្រផលិតម៉ាក Denim នៅកម្ពុជា។ សមត្ថភាពផលិតសម្លៀកបំពាក់ប្រចាំខែរបស់ក្រុមហ៊ុន Q-Port Investments មានចំនួនប្រមាណ ៣៥០ ០០០ ខោអាវ។

លោក Lin បានបង្កើតរោងចក្រដំបូងរបស់ខ្លួននៅកម្ពុជាតាំងពីឆ្នាំ២០០២។ ចាប់តាំងពីពេលនោះមក Q-Port Investments បានបង្កើតឱកាសការងារជាច្រើនសម្រាប់ប្រជាជនក្នុងស្រុក ដែលបានប្រើប្រាស់កម្មករប្រហែល ២ ៨០០ នាក់ក្នុងឆ្នាំ២០១២ ប៉ុន្តែបច្ចុប្បន្នមានកម្មករ ១ ៣០០នាក់។

លោកបានសង្កត់ធ្ងន់ថា ឧស្សាហកម្មកាត់ដេរបានចូលរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា និងជាសសរទ្រូងនៃសេដ្ឋកិច្ចរបស់ប្រទេសសម័យក្រោយសង្គ្រាម។

ទោះយ៉ាងណា ការបង្កើនតម្លៃពលកម្ម និងការប្រកួតប្រជែងពីបណ្ដាប្រទេសនាំចេញសម្លៀកបំពាក់កំពុងលេចធ្លោ បានជំរុញឱ្យក្រុមហ៊ុន Q-Port Investments ផ្ទេរខ្សែចង្វាក់ផលិតកម្មរបស់ខ្លួនមួយចំនួនទៅប្រទេសផ្សេងទៀតដូច បង់ក្លាដែស ជាដើម។

លោក Lin បន្តថា៖«តម្លៃពលកម្មនៅកម្ពុជាបានកើនឡើងជាលំដាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ឡើងពី៤៥ដុល្លារ ដល់១៩០ដុល្លារអាមេរិកនៅឆ្នាំនេះ។ ការសម្រេចរបស់សហភាពអឺរ៉ុបក្នុងការដកផ្នែកខ្លះនៃការអនុគ្រោះពន្ធអ្វីៗទាំងអស់លើកលែងតែអាវុធ (EBA) ចេញពីកម្ពុជា ក៏បានជះឥទ្ធិពលដល់ក្រុមហ៊ុនផលិតសម្លៀកបំពាក់ផងដែរ។


គំរូមជ្ឈមណ្ឌល E-Port Center ដ៏ស្រស់ស្អាត។


លោក Lin Zhi Qiang។

«បន្ថែមពីនេះផលប៉ះពាល់ដ៏ធំធេងដែលបង្កឡើងដោយជំងឺកូវីដ ធ្វើឱ្យការបញ្ជាទិញសរុបរបស់យើងពីអតិថិជនបានធ្លាក់ចុះ៤០ភាគរយ។ ក្រឡេកមើលតម្រូវការទីផ្សាររបស់ប្រទេសនានាក្នុងតំបន់ ឬការបញ្ជាទិញរបស់យើងពីសហរដ្ឋអាមេរិក អឺរ៉ុប និងកាណាដា បានធ្លាក់ចុះ៣០ទៅ៥០ភាគរយ។

ប៉ុន្តែ លោកថ្លែងថា ក្រុមហ៊ុន Q-Port Investments កំពុងមើលឃើញការបញ្ជាទិញកើនឡើងដល់៨០ភាគរយនៃបរិមាណកាលពីឆ្នាំមុន។ លោកមានទំនុកចិត្តចំពោះការងើបឡើងវិញនូវបរិមាណអាជីវកម្មនៃក្រុមហ៊ុនរបស់ខ្លួន។

លោកបញ្ជាក់ថាឧស្សាហកម្មកាត់ដេរនៅកម្ពុជា ធ្លាប់បានផលិតផលិតផលដែលមានគុណភាពទាប និងមធ្យមអស់រយៈពេលជាយូរមកហើយ។ វាដល់ពេលវេលាដែលឧស្សាហកម្មមួយនេះផ្ដោតសំខាន់លើការផលិតផលិតផលដែលមានគុណភាពមធ្យម ឬផលិតផលដែលមានគុណភាពខ្ពស់។ មូលហេតុដែលគួរផលិត ផលិតផលដែលមានគុណភាពខ្ពស់ គឺក្រុមហ៊ុនផលិតអាចទទួលបានប្រាក់ចំណេញខ្ពស់ជាងនេះ។

«តាមគំនិតរបស់ខ្ញុំ កម្មករនៅក្នុងប្រទេសកម្ពុជា បានត្រៀមខ្លួនរួចជាស្រេចក្នុងការផលិតផលិតផលលំដាប់ខ្ពស់»។

លោក Lin ក៏បានផ្ដួចផ្ដើមផែនការសម្រាប់ Q -Port Investments ផងដែរសម្រាប់ការលក់រាយតាមរយៈការជួសជុល និងផ្លាស់ប្ដូរផ្នែកខ្លះនៃរោងចក្ររបស់ក្រុមហ៊ុនទៅជាកន្លែងលក់ទំនិញដែលមានឈ្មោះ E-Port Center៕

ការទាក់ទាញសំខាន់របស់មជ្ឈមណ្ឌលលក់រាយ គឺជាការផ្ដល់ជូននូវសម្លៀកបំពាក់ឃីហោអន្តរជាតិ។ កន្លែងទំនេរផ្សេងទៀត នឹងត្រូវជួលសម្រាប់កន្លែងធ្វើការរួមគ្នា បើកហាងលក់អាហារ ភេសជ្ជៈ និងហាងលក់វត្ថុផ្សេងៗទៀត។

លោក Lin ថ្លែងថា ដោយមានប្រជាជនវ័យក្មេងច្រើន និងអ្នកដែលមានជីវភាពមធ្យមកំពុងកើនឡើងឧស្សាហកម្មលក់រាយនៅកម្ពុជានៅមានសក្ដានុពលយ៉ាងច្រើន៕ ■



# ហុងកុងគឺជាច្រកចូលប្រទេសចិនសម្រាប់សហគ្រាសកម្ពុជា

លោក Lee Shueng Yuen នាយកប្រតិបត្តិការិយាល័យពាណិជ្ជកម្មនិងសេដ្ឋកិច្ចហុងកុង (HKETO) មានមូលដ្ឋាននៅទីក្រុងបាងកក បានគូសបញ្ជាក់ពីរបៀបដែលមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិសំខាន់ៗបានរួមចំណែកដល់សេដ្ឋកិច្ចកម្ពុជា។




**១) តើ HKETO ទទួលបានជោគជ័យយ៉ាងដូចម្ដេច ក្នុងការពន្លឿនពាណិជ្ជកម្មនិងការវិនិយោគមកប្រទេសកម្ពុជាក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ?**

ការិយាល័យ HKETO នៅទីក្រុងបាងកក ត្រូវបានបង្កើតឡើងនៅខែកុម្ភៈឆ្នាំ២០១៩។ វាគឺជាការិយាល័យថ្មីបំផុត និងទី១៣ នៅបរទេស ដែលតំណាងឱ្យរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង។ បេសកកម្មរបស់យើងគឺដើម្បីសម្រួលដល់ការអភិវឌ្ឍទំនាក់ទំនងទ្វេភាគីរវាងហុងកុង និងកម្ពុជា និងប្រទេសចំនួន៣ទៀត ដែលនៅក្បែរនោះគឺមានប្រទេស ថៃ មីយ៉ាន់ម៉ា និងបង់ក្លាដែស ដើម្បីនាំយកកិច្ចសហប្រតិបត្តិការរបស់ហុងកុងជាមួយប្រទេសទាំងនេះឱ្យទៅដល់កម្ពស់និងទិសដៅថ្មី។

នៅឆ្នាំ២០១៩ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងហុងកុង និងកម្ពុជាសម្រេចបាន ១,២ ពាន់លានដុល្លារអាមេរិក។ បើធៀបនឹងឆ្នាំ២០១៦ មានការកើនឡើង ៤,៣ ភាគរយ។ ទាក់ទងនឹងបញ្ហានេះ យើងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងពាណិជ្ជកម្មកម្ពុជា សម្រាប់ការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានហុងកុង ផ្ដល់ដោយកម្ពុជា។

ដោយឡែក ហុងកុង និងកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជៀសវាងការយកពន្ធត្រួតគ្នា កាលពីខែមិថុនា ឆ្នាំ២០១៩ ដើម្បីជំរុញការវិនិយោគ និងពាណិជ្ជកម្មទ្វេភាគីបន្ថែមរវាងភាគីទាំង២។

**២) តើសហគ្រិនហុងកុងមានទស្សនៈបែបណាចំពោះសេដ្ឋកិច្ចកម្ពុជា?**

យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ហុងកុងគឺជាអ្នកវិនិយោគបរទេសដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា។ ក្នុងឆ្នាំ២០១៩ ហុងកុងជាវិនិយោគិនបរទេសធំទី ២ របស់កម្ពុជា ដែលមានទឹកប្រាក់វិនិយោគ ៩១៣ លានដុល្លារអាមេរិក។ សហគ្រិនហុងកុងទាំងនោះ បានវិនិយោគលើវិស័យអាជីវកម្មផ្សេងៗគ្នានៅកម្ពុជា រួមមាន វាយនភណ្ឌនិងសម្លៀកបំពាក់ សណ្ឋាគារ សំណង់ លក់រាយ និងវិស័យដឹកជញ្ជូន។

**៣) តើកម្ពុជាអាចពឹងផ្អែកលើហុងកុងដូចម្ដេច ខណៈហុងកុងត្រូវបានគេស្គាល់ថាជាមជ្ឈមណ្ឌលពាណិជ្ជកម្មនិងហិរញ្ញវត្ថុពិភពលោក ដែលជាច្រកសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ?**

ហុងកុងផ្ដល់នូវគុណប្រយោជន៍ពិសេសសម្រាប់ក្រុមហ៊ុនកម្ពុជា ព្រោះថាវាជាច្រកចូលប្រទេសចិន ដែលមានភាពងាយស្រួល និងមានសុវត្ថិភាពបំផុត។ វាមានអត្ថប្រយោជន៍តែមួយគឺគោលការណ៍"ប្រទេស១ប្រព័ន្ធ២" នៅហុងកុង។ តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់យើងជាមួយប្រទេសចិន ក្រុមហ៊ុននៅហុងកុងរួមទាំងក្រុមហ៊ុនកម្ពុជាផងដែរ ប្រសិនបើពួកគេត្រូវបានបង្កើតឡើងនៅហុងកុង ពួកគេរីករាយនឹងការចូលទៅកាន់ទីផ្សារកាន់តែច្រើន និងងាយស្រួល។

**៤) ជំងឺកូវីដ ១៩ នៅតែបន្តជះឥទ្ធិពលដល់សេដ្ឋកិច្ចនិងពាណិជ្ជកម្មសកល។ តើការផ្ទុះឡើងជំងឺនេះមានឥទ្ធិពលប៉ះពាល់ធ្ងន់ធ្ងរទៅលើទំនាក់ទំនងពាណិជ្ជកម្មរវាងហុងកុងនិងកម្ពុជាឬទេ?**

នៅពេលមានជំងឺរាតត្បាតកូវីដ១៩ បានបង្កឱ្យមានការលំបាកសម្រាប់ការប្រាស្រ័យទាក់ទងទល់មុខគ្នា ប៉ុន្តែវាមិនមានឧបសគ្គសម្រាប់ការបន្តកិច្ចសហប្រតិបត្តិការអាជីវកម្មរវាងហុងកុង និងកម្ពុជាទេ។

ឧទាហរណ៍រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចមកពីប្រទេសសមាជិកអាស៊ានទាំង១០ និងហុងកុងនៃប្រទេសចិន (HKC) នៅថ្ងៃទី ២៨ ខែសីហាឆ្នាំ ២០២០ បានបើកកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ សម្រាប់ពិគ្រោះយោបល់សម្រាប់កិច្ចប្រជុំ(Fourth Asean Economic Minister-HKC Consultations) លើកទី៤ និងបានព្រមព្រៀងលើក កម្ពស់ទំនាក់ទំនងសេដ្ឋកិច្ចរវាងហុងកុងនៃប្រទេសចិន និងអាស៊ាន រួមមានទាំងប្រទេសកម្ពុជាដែរ,តាមរយៈការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី Asean-HKC Free Trade Agreement និងកិច្ចព្រមព្រៀង Asean-HKC Investment agreement។

**៥) តើហុងកុងអាចរួមចំណែកអ្វីខ្លះក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ឧទាហរណ៍ ការធ្វើផែនការទីក្រុង និងហេដ្ឋារចនាសម្ព័ន្ធ?**

សហគ្រាស និងអ្នកជំនាញហុងកុងបានរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជាតាមរយៈគំនិតផ្ដួចផ្ដើមផ្លូវមួយខ្សែក្រវាត់មួយ ដែលផ្ដល់នូវឱកាសជាច្រើនសម្រាប់កិច្ចសហប្រតិបត្តិការទៅវិញទៅមក និងការសហការគ្នា។ ដោយផ្អែកទៅលើគុណសម្បត្តិពិសេសជាច្រើន ក្នុងនាមជាមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ និងមានអ្នកជំនាញច្រើនដែលប្រតិបត្តិការក្រោមស្តង់ដាអន្តរជាតិ ទីក្រុងហុងកុងគឺជាទីតាំងដ៏ល្អបំផុត ដើម្បីក្លាយជាវេទិកាផ្ដល់នូវសេវាកម្មជំនាញក៏ដូចជាជួយសម្រួលដល់លំហូរមូលធន និងគម្រោងហិរញ្ញប្បទាន។ ■




រីករាយ
ទិវាបុណ្យជាតិនៃ
សាធារណរដ្ឋប្រជាមានិតចិន
ថ្ងៃទី១ ខែតុលា ឆ្នាំ២០២០
ខួបលើកទី
៧១
ពីប្រធាន និងសមាជិកគណៈកម្មាធិការប្រតិបត្តិ
THE CHINA HONG KONG & MACAU
EXPATRIATE & BUSINESS ASSOCIATION OF CAMBODIA
HKBAC
柬埔寨香港商會
HONG KONG BUSINESS ASSOCIATION OF CAMBODIA